របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ
និងអគ្គលេខាធិការដ្ឋាន
អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមេសា ឆ្នាំ២០២០

ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

ដោយ ឯកឧត្តម **ឈឹម យិនដារ៉ែត**
អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

មាតិកា

១. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំខែកុម្ភៈ

៤. ភាពប្រឈម

៥. ជំហានបន្តសម្រាប់ខែបន្ទាប់

១. សកម្មភាពការងារបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី

- ១-៩ មេសា ២០២០ ឯកឧត្តមទេសរដ្ឋមន្ត្រី បានតាមដាន និងណែនាំឱ្យមន្ត្រីខុទ្ទកាល័យ ទំនាក់ទំនងសួរសុខទុក្ខពីសុខភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងស្ថានភាពការងាររបស់ប្រជាពលរដ្ឋតាមភូមិ ជាពិសេស ពលករចំណាកស្រុកមកពីខាងក្រៅប្រទេស តាមរយៈមេឃុំ និងប្រធានភូមិ។
- ១០ មេសា ២០២០ បានដឹកនាំកិច្ចប្រជុំវីដេអូខនហ្វឺរេន តាមកម្មវិធី BlueJeans ស្តីពីការពិនិត្យលទ្ធផលសកម្មភាពរបស់ថ្នាក់ដឹកនាំ និងជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ១១-២៩ មេសា ២០២០ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងបានណែនាំឱ្យមន្ត្រីខុទ្ទកាល័យ និងអគ្គលេខាធិការ មកបំពេញការងារដោយផ្លាស់វេនគ្នា ក្នុងស្មារតីប្រុងប្រយ័ត្នខ្ពស់លើវិធានការការពារផ្ទាល់ខ្លួន ក្នុងអំឡុងពេលជំងឺកូវីដ១៩ កំពុងតែរាតត្បាត។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានជំរុញនិងគាំទ្រ ឱ្យដំណើរការអនុវត្តបន្ត នូវផែនការសកម្មភាពការងារនៅ អ.ជ.ប.ជ.អ និងដៃគូរនានា។
- ៣០ ឧសភា ឯកឧត្តមទេសរដ្ឋមន្ត្រី អញ្ជើញអធិបតីភាពដ៏ខ្ពង់ខ្ពស់បើកកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣ ។

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ ផ្តល់យោបល់ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ការងារផ្ទៃក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីនិរន្តភាពនៃដំណើរការផ្ទៃក្នុង អ.ជ.ប.ជ.អ។

ឯកឧត្តម ឆា ផលា

- ដឹកនាំការប្រជុំ FRA (Fund Raising Application) Gfatm ជាមួយក្រុមមន្ត្រីបច្ចេកទេស ស្តីអំពីReducing human rights-related barriers to HIV/TB services សម្រាប់ឆ្នាំ ២០២១-២០២៣ ។
- ដឹកនាំការប្រជុំ បច្ចេកទេសដោយបំបែកសំណើ GF FRA (Fund Raising Application) ទៅជាCore Activities និង PAAR (Priority Above Application Request) ។
- ចូលរួមប្រជុំ FRA (Fund Raising Application) Gfatm ជាមួយក្រុមFRA TWG Secretariatនិង GFATM Country Team (Geneva led by Olivier Carvey) at NCHADS។បានលើកសំណើរអោយNCHADSរៀបចំថវិការួមចំណែកទប់ស្កាត់ covid 19។
- ដឹកនាំការប្រជុំ បច្ចេកទេសដោយបញ្ជាក់ជូនក្រុមFRA TWG Secretariatអំពីថវិកាសំណើរ GF FRA (Fund Raising Application)របស់អជបជអដោយហេតុផលថាអជបជអបានទទួលថវិកាប្រមាណ 334Kក្នុងគម្រោងបច្ចុប្បន្ន(២០១៨ ទៅ២០២០) ។
- រៀបចំបេសកកម្មសម្រាប់ក្រុម CCC OC BBG, BMC and OMC។

- សរសេរលិខិតទៅក្រសួងសុខាភិបាលក្នុងការកាត់បៀវត្ស៤០០០០០ក្នុង១ខែសម្រាប់៥ខែរួមចំណែកទប់ស្កាត់ covid 19។
- ពិភាក្សាជាមួយ UNAIDS អំពីការផ្តល់ TA ដើម្បីរៀបចំនិយាមប្រតិបត្តិដាក់ការឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុង CDP/CIP។
- Virtual Meeting ជាមួយ HE Ros Seilavath , Dr Sok Bunna (Phnom Penh) , Dr Robert Stanley ស្តីពី Future support of USAID after HP+ exit on Sustainability។
- ចូលរួមក្នុងCCC OC trip to BBG and BMC 1) ចូលរួមប្រជុំជាមួយគណកម្មាការមណ្ឌលសុខភាពទួល តាឯកក្រុងបាត់ដំបង 2) ចូលរួមនៅក្នុងIndex Case Testing Refresher Training នៅស្វាយស៊ីសុផុន 3) ចូលរួមពិភាក្សាGroup of Champions Thmar Pourk ។
- ចូលរួមក្នុងកិច្ចប្រជុំប្រចាំខែរបស់អជបជអដែលដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រីនិងផ្តល់យោបល់លើ១) GF FRA (Fund Raising Application) ទៅជាCore Activities និងPAAR (Priority Above Application Request)របស់អជបជអ២)ការដាក់ការឆ្លើយតបនឹងមេរោគអេដស៍ទៅក្នុងCDP/CIPនៅស្រុកបរសេដ្ឋ៣)ពី Future support of USAID after HP+ exit on Sustainability។

- ផ្តល់ជាតុចូលនៅក្នុងMitigating the risk of COVID-19 for people living with NCDsរបស់ក្រុមការងារNCDs។
- ចុះសាកសួរសុខទុក្ខសមាជិកCCCដែលទទួលវះកាត់នៅមន្ទីរពេទ្យ Khmer Soviet ។
- ចុះសាកសួរព័ត៌មានដំណើរការART site នៅមន្ទីរពេទ្យ Khmer Soviet ។
- ប្រជុំបច្ចេកទេសត្រៀមយោបល់ការពារគម្រោងGF FRA (Fund Raising Application) ទៅជាCore Activities និង PAARរបស់អជបជអនៅក្នុងក្រុមFRA TWG Secretariat។
- រៀបចំបទបង្ហាញProcess of Integration of HIV and AIDS in CDP/CIP in Borsedth District/ Kampong Speu
- ចូលរួមផ្តល់បទសម្ភាសន៍ Online ជាមួយ Consultant Rashmi Sharma (ជាមួយ Mr Bhavesh / HP+ , Dr. Srey Mony / HP+,) ស្តីពី AIDS integration in Health System ស្របតាម Policy Measure number 6 នៃសជណ ២១៣។

- ចូលរួមក្នុង HSSP Costing at NCHADS។លើកសំណើរដល់ HP+អោយកែសម្រួល NSP V Costing ដែលឯកសារបច្ចុប្បន្នអាចមានគំលាត 10 M បើធៀបនឹងHSSP Costing របស់ NCHADS។
- ដឹកនាំការប្រជុំអគ្គលេខាធិការដ្ឋានស្តីអំពីProcess of Integration of HIV and AIDS in CDP/CIP in Borsedth District/ Kampong Speu។
- ផ្តល់យោបល់លើ Draft Guidance Note Complementary use of health facility funds for HIV/AIDS activities in Cambodia (Policy Measure #3 SCN#213)ដែលស្នើឡើងដោយ Mr Bhavesh / HP+ , Dr. Srey Mony / HP+។
- រៀបចំCCC OC Field Visit ទៅខេត្ត BBG, BMC និងOMC។
- ផ្ញើចំលើយរបស់ NAA FRAបំភ្លឺសំណួររបស់ Saba on NAA application for the GFATM FRA 2021-2023 (1) Big picture of the proposal 2)Rationale of the PAAR,3) Complementarity with HACC proposal 4) Best way to categorize activities (as per separate modules or incorporated into existing modules) 5)M&E framework))

- ប្រជុំជាមួយHE Roseilavath , Mr Bhavesh / HP+ , Dr. Srey Mony / HP+, ស្តីពីដំណើរការផ្តល់ID Poorដល់ PLHIV at ART sites ដោយគូស algorithm ដើម្បីអោយស្របSCN 213។
- ចូលរួមប្រជុំFRA TWG secretariat នៅ NCHADS with virtual contact to GF Country Team led by Olivier Cavey(Geneva), Saba (India), UNAIDS, WHO, CHAI, Khana, HP+, Linkages/ FHI ដើម្បីផ្តល់យោបល់លើសំណើ សុំថវិកាមូលនិធិសកលពីឆ្នាំ២០២១ដល់២០២៣។ បានផ្តល់យោបល់បច្ចេក ទេសលើកសំណើជារួម(Realistic targets for PrEP, PWID application , Social Enterprise, Model of Friendly services (Chhourk Sar vs RHAC), Private sector involvement in HIV and AIDS response) និងជាពិសេស ការពារគម្រោងរបស់អជបជអ (Reducing human rights-related barriers to HIV/TB services)។

ដឹកនាំការប្រជុំ Grant Management Working Team (NAA GFATM grant) :

- 1) Update on the progress of grant implementation
- 2) Activities to be carried out 1) Supervision 2) Training
- 3) Update on the NAA FRA application for 2021-23
- 4) AOB: Training Tool for the integration of AIDS in CDP/ CIP

លោកជំទាវ ស៊ឹម ខេងខាំ

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី 4 ប្រចាំខែមីនានិងប្រចាំសប្តាហ៍ទី 1 ទី 2 ទី 3 ទី 4 ប្រចាំខែមេសាឆ្នាំ 2020 របស់អគ្គលេខាធិការដ្ឋាន
- ពិនិត្យរបាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែមីនាឆ្នាំ 2020 របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺ Covid 19 រយៈការចូលរួមបរិច្ចាគប្រាក់បៀវត្សជូនទៅគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺ Covid 19
- .ពិនិត្យរបាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមការងារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងចុះធ្វើការអប់រំផ្សព្វផ្សាយអំពីជំងឺអេដស៍ Covid 19 នៅស្រុកបរសេដ្ឋខេត្តកំពង់ស្ពឺ។
- .ចូលរួមកិច្ចប្រជុំប្រចាំខែថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រីប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- .បានតាមដានព័ត៌មានប្រចាំថ្ងៃស្តីពីការរីករាលដាលនៃមេរោគ Covid 19 របស់គណៈឃោសនាអប់រំដើម្បីផ្សព្វផ្សាយបន្ត
- .បានយើញនិងអានព័ត៌មានស្តីពីការបង្ហាករការចម្លងមេរោគអេដស៍ជាសកលសម្រាប់វិស័យមិនមែនសុខាភិបាលដែលរៀបចំដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម ស៊ឹម គឹមសៃន

- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែមិនា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានពិនិត្យទៅលើទិន្នន័យសង្ខេបឆ្នាំ២០១៨ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៨ ដែលរៀបចំ ប់ពុម្ព និងផ្សព្វផ្សាយដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានពិនិត្យរបាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមការងារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចុះធ្វើការងារផ្សព្វផ្សាយជំងឺអេដស៍ និងកូវីដ១៩ នៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។
- បានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដតាមរយៈការចូលរួមថវិកាទៅគណកម្មការប្រយុទ្ធនឹងជំងឺកូវីដ។
- បានចូលរួមកិច្ចប្រជុំប្រចាំខែ តាមរយៈប្រព័ន្ធ Blue Jeans សម្រាប់កិច្ចថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ ខែមេសា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានពិនិត្យឯកសារការបង្ការការចម្លងមេរោគអេដស៍ជាសកលសម្រាប់វិស័យមិនមែនសុខាភិបាល ដែលបានរៀបចំដោយអគ្គលខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ចូលរួមពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានពិនិត្យទៅលើឯកសារស្តីពីយន្តការឆ្លើយតបប្រកបដោយចីរភាពតាមរយៈការធ្វើសមាហរន្តកម្មពង្រឹងប្រព័ន្ធសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

ឯកឧត្តម តែង គន្ធី

- ទំនាក់ទំនងជាមួយគណៈកម្មាធិការ និងលេខាធិកាដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ ខេត្តប៉ៃលិន និងព្រះវិហារ

1. សាកសួរពីស្ថានភាពកូវីត និងផលប៉ះពាល់ទៅនឹងសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ។
2. ស្ថានភាពទូទៅស្ងប់ស្ងាត់ជាងធម្មតា តែអ្នកជម្ងឺ និងអ្នកផ្គុំកមេរោគអេដស៍នៅមកទទួលសេវាតាមធម្មតា ។
3. បុគ្គលិកមួយចំនួនត្រូវចល័តទៅជួយសកម្មភាពប្រយុទ្ធនឹងមេរោគកូរ៉ូណានៅតាមព្រំដែន ។
4. សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលនៅមានបន្តរតែថយចំនួនដងក្នុងការចុះអនុវត្ត។
5. លើកទឹកចិត្តឱ្យមានការបន្តសកម្មភាពអេដស៍ជាពិសេសក្នុងសហគមន៍ ។
6. ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈវីដេអូអនឡាញ
7. ទំនាក់ទំនងជាមួយអង្គការ MHC លើការងារក្រុមបុរសរួមភេទជាមួយបុរស និងក្រុមប្តែងភេទ
8. ពិនិត្យការងាររៀបចំគោលការណ៍ណែនាំជាតិពីការបង្ការការចម្លងមេរោគអេដស៍ជាសកល។

ឯកឧត្តម រស់ សីលវ៉ាត់

- ប្រជុំពិនិត្យឡើងវិញសាចុះឡើង លើកញ្ចប់សកម្មភាពសំនើមូលនិធិសាកលផ្នែក Human Right barrier removal បន្ទាប់ពីទទួលយោបល់ក្នុងកិច្ចប្រជុំរបស់ក្រុមការងាររួមរៀបចំគម្រោងសំនើមូលនិធិសាកល។
- ប្រជុំតាមវីដេអូជាមួយ ក្រុមការងារ USAID ដើម្បីស្វែងរកការពាក់ព័ន្ធបន្តរបស់គេ បន្តក្រោយការបញ្ចប់គម្រោងរបស់ អង្គការអេចភីភ្លើស ហើយជាលទ្ធផល យូអេសអេអាយឌី នឹងមានកញ្ចប់សកម្មភាពខ្លះបន្តជាមួយយើងពិសេសក្នុងការបន្តជម្រុញអនុវត្ត ស.ជ.ណ.២១៣ ដែលក្នុងនោះមានទាំងការជម្រុញអោយមានកញ្ចប់ថវិកាលើការងារអេដស៍នៅឃុំសង្កាត់។
- ចូលរួមប្រជុំថ្នាក់ដឹកនាំថ្ងៃ១០ ខែមេសា ឆ្នាំ២០២០ តាមប្លង់ជិន ពិនិត្យរបាយការណ៍សកម្មភាពខែមីនាឆ្នាំ ២០២០។
- ប្រជុំតាមប្លង់ជិន ជាមួយមន្ត្រីអគ្គលេខាធិការដ្ឋាន ស្តីពីការរៀបចំគោលការណ៍ ក្នុងការធ្វើការជាមួយឃុំសង្កាត់ណែនាំការដាក់បញ្ចូលកញ្ចប់សកម្មភាពអេដស៍ទៅក្នុងកញ្ចប់ផែនការសកម្មភាពឃុំសង្កាត់ឆ្នាំ២០២១ ដោយសាកល្បងពីស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

- ប្រជុំតាមវីដេអូពីរលើកជាមួយក្រុមការងារអង្គការ HP+ លើការជម្រុញការផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដល់អ្នករស់នៅជាមួយមេរោគអេដស៍ និងបានលើសំនើសេនារីយូសម្រាប់ក្រសួងផែនការពិចារណា ហើយ គ្រោងប្រជុំបន្តបន្ទាប់ទៀតនាថ្ងៃ២៨ខែមេសា និងក្នុងខែឧសភាឆ្នាំ២០២០។
- ប្រជុំក្រុមការងារគ្រប់គ្រងមូលនិធិពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តគម្រោងផែនការឆ្នាំ២០២០ និងរកយុទ្ធ វិធីជម្រុញអនុវត្តការងារក្នុងបរិបទនៃការស្ថិតនៅឆ្ងាយពីគ្នាដើម្បីប្រយុទ្ធនឹងការរាលដាលនៃវីរុសកូវីដ១៩។

ឯកឧត្តម ជា ពៅ

- ចុះធ្វើការសិក្សាស្វែងយល់អំពីការងារអេដស៍នៅមន្ទីរពេទ្យបង្អែកស្រុកគងពិសី មណ្ឌលសុខភាពរំពារមានជ័យ និងប្រជុំពិភាក្សាអំពីការដាក់បញ្ចូលការងារអេដស៍ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ នៅឃុំស្វាយរំពារ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។
- តាមដានស្ថានភាពមេរោគកូវីត១៩ និងវិធានការការពារ
- តាមស្រាវជ្រាវស្បែតអប់រំពីជំងឺកូវីត១៩ ដើម្បីយកមកផុសក្នុងFB NAA
- បន្តតាមដាន និងស្រាវជ្រាវឯកសារសម្រាប់ទប់ស្កាត់ការឆ្លង និងចម្លងមេរោគកូរ៉ូណា ១៩ ដើម្បីផុសក្នុងហ្វេសបុកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ពិនិត្យរបាយការណ៍ឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តរតនគិរី ប្រចាំត្រីមាសទី១ ឆ្នាំ២០២០។
- ពិនិត្យសេចក្តីព្រាងទស្សនទានស្តីការរៀបចំធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍថ្នាក់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

- បានផ្ទុសស្បែតអបើរំទាក់ទងនិងជំងឺCovid-19 បាន៩ដង ក្នុងហ្វេសបុកផេករបស់ NAAបានផ្ទុសក្នុងហ្វេសបុកផេកសរុបចំនួន ១៨ដង ទាក់ទងCovid-19 ក្នុងខែមីនា
- បានផ្ទុសក្នុងហ្វេសបុកផេកសរុបចំនួន ៤៣ដង ក្នុងខែមេសា

ឯកឧត្តម ហោ ប៊ុនឆ្លេច

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ខែមិនា ប្រចាំខែ២០២០ របស់អគ្គលេខាធិការដ្ឋាន
- ចូលរួមកិច្ចប្រជុំ online ជាមួយក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិដើម្បីពិភាក្សាលើគម្រោងចូលរួមទប់ស្កាត់ជំងឺកូវីដ១៩
- បានចូលរួមពិភាក្សា Online ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា លើការងាររៀបចំគម្រោងឆ្លើយតបកូវីដ១៩ សម្រាប់គ្រួសារក្រីក្រ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមកិច្ចប្រជុំប្រចាំខែ របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈប្រព័ន្ធ online។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ខែមេសាឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន
- បានចូលរួមកិច្ចប្រជុំ online ជាមួយក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិដើម្បីពិភាក្សាលើការរៀបចំព័ត៌មានស្តីពីចំណេះដឹងជាមូលដ្ឋាននៃជំងឺកូវីដ១៩។

- បានពិនិត្យទៅលើរបាយការណ៍សង្ខេបស្តីពីការត្រួតពិនិត្យអេដស៍ជាសកលឆ្នាំ២០១៩ ដែលបានបញ្ជូនទៅ UNAIDS
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ខែមេសា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- បានរៀបចំសេចក្តីព្រាងព័ត៌មានស្តីពីចំណេះដឹងជាមូលដ្ឋាននៃជំងឺកូវីដ១៩។
- បានពិនិត្យមើលឯកសារទស្សនទាន និងការរៀបចំសកម្មភាព និងថវិកាសម្រាប់ឃុំ១៥ ឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

ឯកឧត្តម ស៊ឹម គឹមសាន

- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៤ ប្រចាំ ខែ មីនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន
- ពិនិត្យរបាយការណ៍កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសប្រចាំខែមីនា ឆ្នាំ២០២០ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺ COVID-19 តាមរយៈការចូលរួមបរិច្ចាកប្រាក់បៀវត្ស ជូនទៅគណៈកម្មាការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺ COVID-19 ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី១ ខែ មេសា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ។
- បានពិនិត្យរបាយការណ៍ស្តីពីសកម្មភាពរបស់ក្រុមការងារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចុះធ្វើការងារអប់រំផ្សព្វផ្សាយ ពីអេដស៍ និង COVID-19 នៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។

- បានចូលរួមកិច្ចប្រជុំប្រចាំខែថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈប្រពន្ធ័ Blue Jeans ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី២ខែមេសា ឆ្នាំ២០២០របស់អគ្គលេខាធិការដ្ឋាន ។
- បានអាន និងពិនិត្យមើលឯកសារស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល សម្រាប់វិសយ័មិនមែនសុខាភិបាល ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ពិនិត្យរបាយការណ៍កិច្ចប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ទី៣ខែ មេសា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន ។
- បានពិនិត្យទៅលើឯកសារស្តីពីយន្តការឆ្លើយតបប្រកបដោយចីរភាពតាមរយៈការធ្វើសមាហរន្តកម្មពង្រឹងប្រពន្ធ័សុខាភិបាល និងវិសយ័មិនមែនសុខាភិបាល ។

២. សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន

ឯកឧត្តម អគ្គលេខាធិការ

- ថ្ងៃទី១០ ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមីនា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី។
- ថ្ងៃទី១៥ បញ្ចប់និងបញ្ជូនរបាយការណ៍នៃការពិនិត្យអេដស៍សកល២០១៩ (Global AIDS Monitoring Report 2019) ទៅការិយាល័យធំ UNAIDS។
- ថ្ងៃទី១៣ ដឹកនាំកិច្ចប្រជុំបច្ចេកទេសអគ្គលេខាធិការដ្ឋានប្រចាំសប្តាហ៍។
- ថ្ងៃទី១៦ ដឹកនាំកិច្ចប្រជុំបច្ចេកទេសអគ្គលេខាធិការដ្ឋាន ដោយមានការចូលរួមពីអង្គការ HP+ ដើម្បីពិភាក្សានិងសិក្សាអំពីការចូលរួមអនុវត្តនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាពស្របតាមការប្រែប្រួលថ្មីៗនៃការធ្វើវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ជាពិសេសការផ្ទេរទាំងមុខងារ និងថវិកាលើវិស័យសុខាភិបាលទៅរដ្ឋបាលរាជធានី ខេត្ត។
- ថ្ងៃទី១៧ ចូលរួមកិច្ចប្រជុំក្រោមការដឹកនាំរបស់ឯកឧត្តម ទា ផលា ដើម្បីរៀបចំកិច្ចពិភាក្សាលើការរៀបចំការងារសមាហរណ៍កម្មការងារអេដស៍នៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។
- ថ្ងៃទី២០ ដឹកនាំកិច្ចប្រជុំរួមប្រចាំខែមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ។
- ថ្ងៃទី២១ ដឹកនាំកិច្ចប្រជុំពិភាក្សារៀបចំពិនិត្យកែសម្រួលទស្សនទានស្តីការរៀបចំធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍនិងរៀបចំធ្វើគម្រោងថវិកាសម្រាប់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ សម្រាប់ ជាការអនុវត្តនៅទូទាំងប្រទេស។

- ថ្ងៃទី២៤ ចូលរួមកិច្ចប្រជុំក្រុមគ្រប់គ្រងជំនួយ ដោយពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តមូលនិធិសកល ២០១៨-២០២០ និងសំណើមូលនិធិសកលថ្មីឆ្នាំ២០២១-២០២៣។
- ថ្ងៃទី២៧ កិច្ចប្រជុំបច្ចេកទេសអគ្គលេខាធិការដ្ឋានពិនិត្យកែសម្រួលគោលការណ៍ណែនាំស្តីពីការប្រុងប្រយ័ត្ន ជាសកលចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។
- ថ្ងៃទី២៨ ចូលរួមកិច្ចពិភាក្សាតាមZoom រកយន្តការនៃការផ្តល់អត្តសញ្ញាណកម្មក្រីក្រដល់អ្នកផ្ទុកមេរោគអេដស៍ ដោយមានការចូលរួមពីតំណាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងផែនការ NCHADS, UNAIDS និងHP+។
- ថ្ងៃទី៣០ ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣។
- បន្តរៀបចំពាក្យបំព្រួញទាក់ទងនឹងការងារមេរោគអេដស៍ និងជំងឺអេដស៍
- ពិនិត្យ ផ្តល់យោបល់លើការងារបច្ចេកទេស រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំថ្ងៃ ជូន ឯកឧត្តមទេសរដ្ឋមន្ត្រី។

នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

- បានរៀបចំទុកដាក់ឯកសារចេញ-ចូលក្នុងនាយកដ្ឋានឱ្យមានរបៀបរៀបរយ បញ្ជូន និងតាមដាន រាល់ឯកសារដែលចេញពីនាយកដ្ឋានទៅថ្នាក់ដឹកនាំត្រួតពិនិត្យ និងចុះហត្ថលេខាតាមឋានានុក្រម។
- បានរៀបចំធ្វើគម្រោងសកម្មភាពសម្រាប់ស្នើសុំទៅមូលនិធិសកល (Global Fund)។
- បានរៀបចំផែនការវិនិយោគសាធារណៈ ៣ឆ្នាំរំកិល (PIP) ឆ្នាំ២០២១-២០២៣ ដើម្បីដាក់ជូនក្រសួងផែនការ ។
- បានចូលរួមប្រជុំពិភាក្សាការងារជាមួយទីប្រឹក្សាព័ត៌មានយុទ្ធសាស្ត្រ UNAIDS ស្តីពីរបាយការណ៍វឌ្ឍនភាពឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ជូនអង្គការសហប្រជាជាតិ ហើយក៏បានទាក់ទងជាមួយ NCHADS ដើម្បីទទួលទិន្នន័យរបស់ GAM 2019 ក្នុងនោះផងដែរខាងនាយកដ្ឋានបានធ្វើការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ GAM data online tool បាន ១០០% ហើយ។
- បានរៀបចំធ្វើវាក្យស័ព្ទសម្រាប់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- បានបកប្រែជាភាសាខ្មែរនូវផែនការយុទ្ធសាស្ត្រជាតិជាពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ ឆ្នាំ២០១៩-២០២៣។
- បានរៀបចំ និងពិនិត្យផែនការសកម្មភាព របស់អគ្គលេខាធិការដ្ឋាន និងរបស់នាយកដ្ឋាន PMER នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០២០។

នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ

- បានរៀបចំ និងបញ្ជូនលិខិតរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ស្តីពីការបរិច្ចាគប្រាក់ខែជា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ចំនួន ៥០ភាគរយ ចំនួន៥ខែ គឺពីខែមេសា ដល់សីហា ឆ្នាំ២០២០ ជូនគណៈកម្មាធិការប្រយុទ្ធនឹងជំងឺកូវីដ១៩។
- បានបញ្ជូនលិខិតរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ស្តីពី ការបរិច្ចាគប្រាក់ខែជូនគណៈកម្មាធិការប្រយុទ្ធនឹងជំងឺកូវីដ១៩ ទៅក្រសួងសុខាភិបាល ព្រមទាំងចម្លងជូន ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ។
- តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹង ជំងឺអេដស៍ នាយកដ្ឋានបានទិញកម្មវិធី BlueJeans ដែលជាកម្មវិធីសម្រាប់ការរៀបចំ កិច្ចប្រជុំតាមបណ្តាញអ៊ីនធឺណេត ដើម្បីដាក់ឱ្យប្រើប្រាស់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងដំណាក់កាលនៃការរាលដាលមេរោគកូវីដ១៩។

- បានប្រជុំប្រចាំសប្តាហ៍នាយកដ្ឋាន ចំនួន១ដង តាមកម្មវិធី BlueJeans ដែលជាកម្មវិធីសម្រាប់ការរៀបចំកិច្ចប្រជុំតាមបណ្តាញអ៊ីនធឺណេត នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០។ កិច្ចប្រជុំបានពិភាក្សាអំពី ៖ ១) ការបែងចែកមន្ត្រីបំពេញការងារក្នុងពេលបុណ្យចូលឆ្នាំដែលរាជរដ្ឋាភិបាលបានលើកពេលឈប់សម្រាក ដើម្បីទប់ស្កាត់ការឆ្លងរាលដាលមេរោគកូវីដ១៩ ២) ការសម្អាតអគារ និងទីធ្លាអាជ្ញាធរ ការតុបតែងលម្អព្រះឆាយាល័ក្ខណ៍ តាំងភ្លើង ចងបដា ដូរទង់ជាតិ នឹងរៀបចំរណ្តាប់ទទួលទេវតាឆ្នាំថ្មី ៣) ការកែតម្រូវថវិកាទៅតាមគោលការណ៍វិចារណកម្មលើកទី២របស់រាជរដ្ឋាភិបាល ៤) ការកែតម្រូវឯកសារលទ្ធកម្ម និង៥) ការពន្លឿនឯកសាររដ្ឋទេយ្យ។

នាយកដ្ឋាន បង្ការ ថែទាំ និងគាំទ្រ

- បានប្រជុំប្រចាំខែក្នុងនាយកដ្ឋាន១លើក និងបានរៀបចំផែនការរបស់នាយកដ្ឋាន ដើម្បី លើកផែនការសកម្ម ភាពសម្រាប់អនុវត្តបន្ត និងពង្រឹងការៈកិច្ចទទួលខុសត្រូវ របស់ មន្ត្រីក្នុង
- បានចូលរួមប្រជុំពិនិត្យផែនការឆ្នាំ ២០២១ និង ២០២៣ របស់ អ.ជ.ប.ជ.អ។
- បានធ្វើការប្រមូលទិន្នន័យពីក្រុមប្រជាជនគន្លឹះ ដើម្បីៈ បានព័ត៌មានថ្មីៗពីចំនួន KP, PLHIV, VCCT, MSM/TG, FEW
- បានប្រជុំរៀបចំផែនការនាយកដ្ឋាន សម្រាប់អនុវត្តសកម្មភាព របស់មូលនិធិសកល ត្រីមាសទី២ និងទី៣ឆ្នាំ២០២០ៈ បានពិនិត្យផែនការអាថិភាព របស់នាយកដ្ឋាន និងបានលើកផែនការសកម្មភាពសម្រាប់គម្រោងបន្ទាប់(ត្រីមាសទី៤)
- បានចូលរួមប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ និងប្រចាំខែ ដឹកនាំប្រជុំ ដោយ ឯកឧត្តម ប្រធាន និង ឯកឧត្តមអគ្គលេខាធិការ តាមរយៈវីដេអូ Conference.
- បានបន្តពិនិត្យ និងកែសម្រួល អោយប្រសើរឡើង ពីគោលការណ៍ណែនាំស្តីពីការការពារ មេរោគអេដស៍ជាសកលៈ បានកែរសម្រួល តាមអនុសាសន៍ណែនាំ របស់ ឯកឧត្តម ទេសរដ្ឋមន្ត្រីនិងបានដាក់ជូន ឯកឧត្តម អនុប្រធាន តែង គន្ធី ពិនិត្យ និងផ្តល់អនុសាសន៍។

- បានបន្តរៀបចំ និងពិនិត្យឡើងវិញ លើប្លង់មេរៀន សម្រាប់ធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីបរិយាកាសគាំទ្រ និងការឆ្លើយតបមេរោគអេដស៍ នឹងជំងឺអេដស៍តាមរយៈដៃគូ
- សហគមន៍ ៖បានពិនិត្យកែសម្រួលវិធីសាស្ត្រ និងខ្លឹមសារមេរៀន
- ធ្វើអោយប្រសើរថែមទៀតនូវគុណភាពស្តាយបង្ហាញពិនិត្យពេលម៉ោង អោយបានសមស្រប, ជ្រើសរើសវីដេអូនិងខ្លឹមសារវីដេអូឃ្លីប សម្រាប់អប់រំបន្ត
- បានបន្តរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីការបង្កបរិយាកាសអំណោយផលសម្រាប់ក្រុមប្រជាជនគន្លឹះក្នុងការឆ្លើយតបមេរោគអេដស៍នឹងជំងឺអេដស៍នៅថ្នាក់ខេត្តនិង រាជធានី៖
- បានពិនិត្យលើរបាយការណ៍អនុវត្តកន្លងមក
- បានពិនិត្យស្ថានភាពថ្នាក់ខេត្តដែលស្នើឡើងក្នុងកិច្ចប្រជុំដើម្បីធ្វើការដោះស្រាយ។
- បានលើកទិសដៅសម្រាប់អនុវត្តនៅត្រីមាសបន្ទាប់

- បន្តរៀបចំផ្តល់វគ្គបណ្តុះបណ្តាលគ្រូបង្គោលពី EE-MCPI-DD សម្រាប់ខេត្ត ស្វាយរៀង, សៀមរាប និងត្បូងឃ្មុំ ។
- បានរៀបចំរបាយការណ៍កិច្ចប្រជុំផ្សេងៗសម្រាប់អគ្គលេខាធិការដ្ឋាន ថ្នាក់ដឹកនាំ និងដៃគូពាក់ពន្ធ័។

នាយកដ្ឋាន ទាក់ទង និងចលនាប្រកពធនធាន

- បែងចែកវេនប្រចាំការសម្រាប់បុគ្គលិកក្នុងនាយកដ្ឋានទាក់ទង និងចលនាប្រកពធនធាន
- ជំរុញបុគ្គលិកដែលប្រចាំការកន្លែងធ្វើការអនាម័យដើម្បីការពារកូវីដ១៩
- ស្រង់ទិន្នន័យអ្នកផ្ទុកមេរោគអេដស៍តាមឃុំសម្រាប់ចងបញ្ជីអាទិភាពសម្ភាសន៍ទទួលប័ណ្ណសមធម៌
- ស្រង់បញ្ជីកែសម្រួលសមាសភាពក្រុមប្រឹក្សាបច្ចេកទេសតាមខេត្តដែលយឺតយាវ
- ចូលរួមប្រជុំពិនិត្យក្របខ័ណ្ឌសកម្មភាពក្នុងលើកគម្រោងមូលនិធិសកលឆ្នាំ២០២១-២០២៣
- ចូលរួមប្រជុំvideo conference ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី អៀង មូលី
- ចុះបេសកកម្មទៅខេត្តបាត់ដំបង បន្ទាយមានជ័យ និងឧត្រមានជ័យ ដើម្បីស្វែងយល់ពីបទពិសោធន៍ ឆ្លើយតបមេរោគអេដស៍នៅសង្កាត់ទួលតាឯក ករណីបោះបង់ និងViral Supression
- ចូលរួមប្រជុំបច្ចេកទេស តាមរយៈ Video conference ក្រោម អធិបតីភាព ឯកឧត្តម អគ្គលេខាធិការ

- ចងក្រងបញ្ជីឈ្មោះ និងសាអេឡិកត្រូនិក សមាជិក ក្រុមប្រឹក្សា បច្ចេកទេសដើម្បីរៀបចំប្រជុំ Video Conference
- សេចក្តីព្រាងលិខិតផ្លូវការក្នុងការបញ្ជូនបញ្ជីឈ្មោះអ្នករស់នៅជាមួយមេរោគអេដស៍ទៅក្រសួងផែនការ
- ចងក្រងបទពិសោធន៍ស្តីពីមាតិកាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (គណនីឬអនុគណនី)ចំណាយ និងទូទាត់សង្កាត់ទួលតាឯក
- ប្រជុំពិគ្រោះយោបល់ផ្តល់ធាតុចូលលើទស្សនទាន (Concept Note) ស្តីពីសមាហរណកម្ម ការឆ្លើយតបមេរោគអេដស៍ក្នុង ផែនការអភិវឌ្ឍឃុំ សង្កាត់
- ចូលរួមប្រជុំVideo Conference ក្រោមអធិបតីភាព ឯកឧត្តម អគ្គលេខាធិការ ស្តីពីទស្សនទាននៃសមាហរណកម្មកម្មវិធីអេដស៍ ក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់
- ប្រជុំពិគ្រោះយោបល់ផ្តល់ធាតុចូលលើទស្សនទាន (Concept Note) តារាងគណនី អនុគណនី ដើម្បី សមាហរណកម្ម ការឆ្លើយតបមេរោគអេដស៍ក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ក្នុងស្រុកបសេដ្ឋ

ការចាត់តាំងប្រភពមូលនិធិសកល

Progress (Jan-Apr)

Activities Planned	Implemented	Postponed	Percentage	Remarks
(22) training, supervision, meeting, recruit consultant	(12) 2 training 5 supervisions 4 meetings 1 Recruitment	(10) 4 meetings 1 training 5 supervisions	54%	The activities that gather people in group are not possible to implement due to COVID

Fund Request Application (FRA) 2021-23

Description	Budget (in USD)			
	Y1	**Y2**	**Y3**	**Total**
Core Activities				
I-MCPI (Most AT risk Population Community Program Initiative and building and improving Enabling Environment)	6,770	6,770	-	13,540
II. Gender Based Violence (GBV)	8,380	8,380	-	16,760
III. CIP/CDP: This component is about to assist commune council to develop HIV AIDS plan	64,295	80,303	85,906	230,504
IV. Grant management, Administrative and Running Cost	25,146	25,346	27,346	77,838
Total	**104,591**	**120,799**	**113,252**	**338,642(334K)**
Prioritized Above Allocative Request (PAAR) FOR FIVE MORE PROVINCES				
V. CIP/CDP: This component is about to assist commune council to develop HIV/AIDS plan in their commune plans (number of commune council trained, and number of commune councils integrate HIV response in their plans).		69,235	93,352	162,587
Total	**-**	**69,235**	**93,352.00**	**162,587**
Grand total	**104,591**	**190,034**	**206,604**	**501,229**

៣. សមិទ្ធផលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ខែមីនា

- បានបញ្ជូនរបាយការណ៍នៃការពិនិត្យអេដស៍សកល២០១៩ (Global AIDS Monitoring Report 2019) ទៅទីស្នាក់ការធំ UNAIDS។
- បញ្ជូនបញ្ជីឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ចំនួន១.០៦២នាក់ នៃខេត្តចំនួន៨ ទៅក្រសួងផែនការដើម្បីដាក់បញ្ចូលទៅក្នុងដំណើរការនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ សម្រាប់ឆ្នាំ២០២០។
- បញ្ចប់ទស្សនទានស្តីការរៀបចំធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍ និងរៀបចំធ្វើគម្រោងថវិកាសម្រាប់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ សម្រាប់ ជាការអនុវត្តនៅទូទាំងប្រទេស។
- បានបញ្ចប់សេចក្តីព្រាងពាក្យបំព្រួញទាក់ទងនឹងការងារមេរោគអេដស៍ និងជំងឺអេដស៍។
- បានបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គោលការណ៍ណែនាំ
ស្តីពី
ការបង្ការការចម្លងមេរោគអេដស៍ជាសកល

ខែមិថុនា ឆ្នាំ២០២០

រៀបចំដោយៈ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការណែនាំស្តីពី
ការការពារមេរោគអេដស៍ និងជំងឺអេដស៍

ខែមិថុនា ឆ្នាំ២០២០

រៀបចំដោយៈ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៤. តារាងប្រឈម

- ស្ថានភាពកូវីដ១៩ ធ្វើឱ្យការងារមួយចំនួនត្រូវពន្យារពេលអនុវត្ត ដោយឡែកសកម្មភាពនៃគម្រោងមូលនិធិសកល
- មិនទាន់ទទួលបានសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ នៅឡើយ
- ការអនុវត្ត ស.ជ.ណ ២១៣ (២១ កុម្ភៈ ២០១៩) នៅមិនទាន់បានបង្កើតយន្តការឆ្លើយតបសមស្របនៅឡើយ ដើម្បីធានាចីរភាពនៃការឆ្លើយតប៖

✓វិធានការទី១

✓វិធានការទី២

✓វិធានការទី៣

៥. ជំហានបន្ត សម្រាប់ខៃបន្ទាប់

- បន្តសម្របសម្រួលឱ្យក្រសួង ស្ថាប័ន រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២១។
- បញ្ជូនសេចក្តីព្រាងពាក្យបំព្រួញទាក់ទងនឹងការងារមេរោគអេដស៍ និងជំងឺអេដស៍ទៅ NCHADS, UNAIDS, CCC Secretariat ដើម្បីផ្តល់យោបល់បន្ថែម។
- បញ្ជូនលិខិតផ្លូវការទៅក្រសួងសុខាភិបាល ដើម្បីផ្តល់យោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការបង្ការការចម្លងមេរោគអេដស៍ជាសកល។
- ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២១-២០២៣ និងកញ្ចប់ថវិកាឆ្នាំ២០២១
- ត្រៀមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២០
- ត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៤ ឆ្នាំ២០២០
- រៀបចំកម្មវិធីបណ្តុះបណ្តាលស្តីពីធ្វើសមាហរណកម្ម កម្មវិធីអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

- បន្តតាមដាន និងចូលរួមអនុវត្ត ស.ជ.ណ ២១៣។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីដំណើរការនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- រៀបចំធ្វើសេចក្តីសម្រេចតែងតាំងសមាសភាពសមាជិកក្រុមប្រឹក្សាបច្ចេកទេសជាផ្លូវការ។
- ការងារចុះអភិបាលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តាខេត្តមួយចំនួន។
- បំពេញកិច្ចការផ្សេងៗទៀត តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ ។

សូមអរគុណ!